**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-May-2016, 13:06
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (សំណើសុំឯកសារ) ទាក់ទិននឹង Alexander Laban Hinton (2-TCE-88)**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា**
សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
សួន វិសាល
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
DY Socheata

**ផ្ញើជូន៖**

**សហមេធាវីការពារក្តី ខៀវ សំផន**
គង់ សំអុន
Anta GUISSÉ

**សហព្រះរាជអាជ្ញា៖**
ជា លាង
Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

## I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង សហមេធាវីរបស់លោក នួន ជា (បន្ទាប់ពីនេះទៅហៅថា "មេធាវីការពារក្ដី") ដាក់សំណើនេះជូនអង្គជំនុំជម្រះសាលាដំបូងសុំបង្គាប់ឱ្យលោក Alexander Laban Hinton (2-TCE-88) ផ្ដល់កំណត់ហេតុសម្ភាសន៍នានាដែលគាត់បានធ្វើឡើងនៅក្នុងការរៀបចំសរសេរសៀវភៅរបស់គាត់ដែលមានចំណងជើងថា *ហេតុអ្វីបានជាពួកគេសម្លាប់?* (*Why Did They Kill?*)[1] ទៅមេធាវីការពារក្ដី។ មេធាវីការពារក្ដីសន្និដ្ឋានថា ការពិនិត្យមើលឯកសារទាំងនោះ មានសារៈសំខាន់ជាចាំបាច់ក្នុងការវាយតម្លៃអំពីភាពត្រឹមត្រូវនៃការអះអាងរបស់លោក Hinton និងទម្ងន់ដែលត្រូវផ្ដល់ទៅឱ្យភ័ស្ដុតាងរបស់គាត់នោះ។

## II. សាវតារ

2. នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីទាំងអស់ថា លោក Hinton ត្រូវផ្ដល់សក្ខីកម្មនៅក្នុងអំឡុងសប្ដាហ៍ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦[2]។ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា លោក Hinton នឹងត្រូវកោះហៅក្នុងនាមជាសាក្សីជំនាញដើម្បីឱ្យមកផ្ដល់សក្ខីកម្មអំពី "បញ្ហាទាំងអស់ដែលគាត់ដឹង ឬស្ថិតក្នុងជំនាញរបស់គាត់ ដែលទាក់ទិនជាចម្បងទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាម និងពុទ្ធសាសនិក នៅក្នុងសំណុំរឿង ០០២/០២"[3]។ លោក Hinton បានផ្ដល់សក្ខីកម្មនៅចន្លោះពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦[4]។

### ក. ប្រភេទនៃបុគ្គលដែលលោក Hinton បានធ្វើសម្ភាសន៍

3. ក្នុងអំឡុងពេលផ្ដល់សក្ខីកម្មរបស់គាត់ លោក Hinton ត្រូវបានចោទសួរអំពីវិធីសាស្ត្រដែលយកមកប្រើដើម្បីរៀបចំសរសេរសៀវភៅរបស់គាត់ដែលមានចំណងជើងថា *Why Did They Kill?* ។

---

[1] ឯកសារ **E3/3346** និពន្ធដោយ Alexander Hinton មានចំណងជើងថា *Why Did They Kill?*

[2] អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីទាំងអស់ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦។

[3] អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីទាំងអស់ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦។

[4] សូមមើល ប្រតិចារឹកសវនាការ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/401.1**), ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**), ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**), ប្រតិចារឹកសវនាការ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/404.1**)។

គាត់បានពន្យល់ថា ប្រភពរបស់គាត់មានបី៖ បុគ្គលនានា ("ប្រភពមនុស្ស") ស្នាដៃរបស់អ្នកសិក្សាស្រាវជ្រាវដទៃទៀត និងឯកសារនានា[5]។

4. ទាក់ទិននឹងប្រភេទទីមួយ លោក Hinton បានផ្តល់សក្ខីកម្មថា គាត់បានធ្វើសម្ភាសបុគ្គលនានាដែលជាអតីតកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ អ្នកជាប់ឃុំឃាំង និងអ្នកយាមមន្ទីរ ស-២១ ព្រមទាំងប្រជាជនរស់នៅក្នុងភូមិបាយ័ន និងប្រជាជនរស់នៅក្រុងកំពង់ចាម នៅតំបន់ ៤១[6]។ នៅក្នុងរាជធានីភ្នំពេញ លោក Hinton បានធ្វើសម្ភាសជាមួយអ្នកកាសែត អ្នកធ្វើការផ្នែកសិទ្ធិមនុស្ស អ្នកនយោបាយ អ្នកស្គាល់បន្តិចបន្តួច[7] និងបុគ្គលដែលអះអាងថាធ្វើការនៅមន្ទីរ ស-២១[8]។

5. លោក Hinton បានផ្តល់សក្ខីកម្មថា នៅក្នុងអំឡុងពេលចុះសិក្សាស្រាវជ្រាវមកកាន់ប្រទេសកម្ពុជានៅមុនឆ្នាំ ២០០២ (នៅពេលដែលគាត់រៀបចំបញ្ចប់ការសរសេរសៀវភៅរបស់គាត់)[9] គាត់បានជួបជាមួយមនុស្សប្រហែលពី ១៥០ នាក់ ទៅ ២០០ នាក់[10]។ លោក Hinton បានបែងចែកប្រភពមនុស្សរបស់គាត់ជា "អ្នកផ្តល់ព័ត៌មានគន្លឹះ" ដែលគាត់ហៅថាជាមនុស្សដែលគាត់ត្រូវ "ធ្វើសម្ភាសន៍លម្អិតស៊ីជម្រៅ" ម្តង ឬច្រើនដង និងបុគ្គលដែលគាត់ជួបសន្ទនាធម្មតា ដែលនេះជាវិធីសាស្ត្រមួយដែលគាត់ហៅថាជា "ការសង្កេតទៅលើអ្នកចូលរួម"[11]។

---

[5] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ (ភាសាអង់គ្លេស) ១៤ បន្ទាត់ ២១ ដល់ទំព័រ ១៥ បន្ទាត់ ២១, ទំព័រ ១០៥ បន្ទាត់ ១២ ដល់ទំព័រ ១០៦ បន្ទាត់ ៥។

[6] ប្រតិចារឹកសវនាការ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/401.1**) ទំព័រ ៣៧ បន្ទាត់ ១២-២៤។

[7] ឯកសារ **E3/3346,** ERN EN 00431463។ ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរឡើយ។

[8] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ១៧ បន្ទាត់ ២១-២៥។

[9] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ២៦ បន្ទាត់ ១៩-២០។

[10] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៩ បន្ទាត់ ១២-១៤ និងទំព័រ ១៧ បន្ទាត់ ១១-១៦។

[11] ប្រតិចារឹកសវនាការ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/401.1**) ទំព័រ ១៣ បន្ទាត់ ៥-២២។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១០៦ បន្ទាត់ ១-២, ទំព័រ ១១៥ បន្ទាត់ ១៥-១៦។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៩ បន្ទាត់ ៤-២៣។

6. នៅពេលអង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យផ្ដល់ការពិពណ៌នាលម្អិតអំពីបុគ្គលដែលគាត់បានជួបនោះ លោក Hinton បានផ្ដល់ព័ត៌មានដូចតទៅ៖ គាត់បានជួបសម្ភាសច្រើនលើកច្រើនសាជាមួយមនុស្សប្រហែល ១០ នាក់ ទៅ ២០ នាក់ ហើយការធ្វើសម្ភាសន៍តែម្ដងជាមួយបុគ្គលមួយចំនួនដែលមានរយៈពេលពី ៣០ នាទី ទៅ ២ ម៉ោងក្នុងការសម្ភាសន៍នីមួយៗ។ ដំបូង គាត់ធ្វើការអង្កេតទៅលើមនុស្ស ៩៥ គ្រួសារ ទៅ ១០០ គ្រួសារ នៅក្នុងភូមិបាយ័ន ដែលគាត់ត្រូវចំណាយពេលពីរបីម៉ោងជជែកជាមួយតំណាងគ្រួសារនីមួយៗ។ លើសពីនេះទៀត លោក Hinton បានផ្ដល់សក្ខីកម្មថា គាត់បានជួបជាមួយបុគ្គលផ្សេងៗទៀត បន្ទាប់ពីការអង្កេតនេះ[12]។ សរុបទៅ លោក Hinton បានផ្ដល់សក្ខីកម្មថា គាត់បានធ្វើសម្ភាសនៅក្នុងរយៈពេលផ្សេងៗគ្នាជាមួយនឹងមនុស្សប្រហែល ១៥០ នាក់ ទៅ ២០០ នាក់[13]។ សរុបសេចក្ដីទៅ លោក Hinton បានបែងចែកប្រភេទនៃកិច្ចសម្ភាសន៍នោះជាបី គឺ មនុស្សដែលគាត់ធ្វើសម្ភាសច្រើនលើកច្រើនសា មនុស្សដែលគាត់ធ្វើសម្ភាសតែម្ដង និងចុងក្រោយគឺមនុស្សដែលគាត់ជួបសន្ទនាទូទៅ[14]។

7. លោក Hinton ក៏បានផ្ដល់សក្ខីកម្មផងដែរអំពីការអង្កេតមួយដែលគាត់បានរៀបចំឡើងនៅពេលដែលគាត់បានមកដល់ភូមិបាយ័នដំបូងក្នុងឆ្នាំ ១៩៩៤-១៩៩៥ ដែលនៅក្នុងនោះមានសំណួរពាក់ព័ន្ធនឹងបទពិសោធន៍របស់បុគ្គលផ្ទាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[15]។ លោក Hinton បានផ្ដល់សក្ខីកម្មថា មនុស្សប្រហែល ១០០ នាក់ បានឆ្លើយទៅនឹងការអង្កេតរបស់គាត់[16]។

8. ទាក់ទិននឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាម លោក Hinton បានផ្ដល់សក្ខីកម្មថា គាត់បាននិយាយជាមួយមនុស្ស "ប្រហែល ៦ នាក់" នៅភូមិពោធិ៍ ដែលបាននិយាយពីការចាប់ខ្លួន និងការ

---

[12] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ១៧ បន្ទាត់ ១១-១៦។

[13] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៩ បន្ទាត់ ១២-១៤ និងទំព័រ ១៧ បន្ទាត់ ១១-១៦។

[14] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ១៧ បន្ទាត់ ៥-១៦, ទំព័រ ១៨ បន្ទាត់ ២-៨។

[15] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ១៣ បន្ទាត់ ២៣ ដល់ទំព័រ ១៤ បន្ទាត់ ១៥។

[16] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៩ បន្ទាត់ ១២-១៤។

សម្លាប់ជនជាតិវៀតណាម[17]។ នៅពេលគាត់ធ្វើការអង្កេតនៅភូមិពោធិ៍ក្នុងឆ្នាំ ១៩៩៤-១៩៩៥ អ្នកភូមិជាច្រើននាក់បានប្រាប់គាត់ថា ជនជាតិវៀតណាមទាំងអស់ត្រូវបានគេសម្លាប់នៅក្នុងភូមិ ទោះបីពុំមានជនជាតិភាគតិចវៀតណាមច្រើននាក់រស់នៅក្នុងតំបន់នេះក៏ដោយ[18]។ គាត់ក៏បាននិយាយជាមួយ "ទិព្វ" ជាមួយមនុស្សម្នាក់ទៀតដែលបានធ្វើការនៅមន្ទីរស្រុក និងជាមួយ "មនុស្សពីរបីនាក់ដែលពីមុនជាប្រធានភូមិ" ពាក់ព័ន្ធនឹងការសម្លាប់ជនជាតិវៀតណាមនៅតំបន់ ៤១[19]។

9. ក្នុងអំឡុងពេលសួរដេញដោលដោយមេធាវីការពារក្តី លោក Hinton បានផ្តល់សក្ខីកម្មថា ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលបានផ្តល់ដោយបុគ្គលដែលគាត់បាននិយាយជាមួយ គាត់បានប្រើប្រាស់ដំណើរការមុំបី ក្នុងគោលបំណងប្រៀបធៀបព័ត៌មានដែលបុគ្គលម្នាក់ផ្តល់ឲ្យ ជាមួយនឹងព័ត៌មានរបស់បុគ្គលផ្សេងទៀត[20]។

10. លោក Hinton បានផ្តល់សក្ខីកម្មថា គាត់មានខ្សែអាត់សំឡេង ប្រតិចារឹក និង/ឬ កំណត់ត្រានៃកិច្ចសម្ភាសន៍របស់គាត់ និងការស្រាវជ្រាវរបស់គាត់[21]។

## ខ. ការប្រើរហស្សនាម

11. នៅក្នុងសៀវភៅរបស់គាត់ លោក Hinton ប្រើរហស្សនាម ដើម្បីយោងទៅដល់បុគ្គលដែលគាត់បាននិយាយជាមួយ[22] និងយោងទៅដល់បុគ្គលក្នុងន័យទូទៅ ដូចជា "ប្រធានភូមិក្នុងសម័យកម្ពុជា

---

[17] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ២០ បន្ទាត់ ១១ ដល់ ១៤។

[18] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៩ បន្ទាត់ ១៥ ដល់ ១៩។

[19] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៩ បន្ទាត់ ៥ ដល់ ១០។

[20] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ៧៣ បន្ទាត់ ៧ ដល់ ១៩, ទំព័រ ៧៤ បន្ទាត់ ១៤ ដល់ ១៦។

[21] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៧ បន្ទាត់ ១១ ដល់ ២០។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៥ បន្ទាត់ ១៩ ដល់ ២០។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៦ បន្ទាត់ ៧ ដល់ ៨។

[22] ឯកសារ **E3/3346** លេខ ERN 00431743 (ភាសាអង់គ្លេស) (ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ)៖ "តទៅនេះ ខ្ញុំប្រើរហស្សនាមសម្រាប់មនុស្សដែលខ្ញុំបានធ្វើសម្ភាសន៍ និងបានដកស្រង់សម្តីនៅក្នុងការសិក្សានេះ។ ខ្ញុំប្រើប្រាស់ឈ្មោះ

ប្រជាធិបតេយ្យមកពីភូមិពោធិ៍"[23] "អ្នកភូមិពោធិ៍ម្នាក់ដែលជា "ប្រជាជនចាស់" ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ"[24] ឬ "បុរសកម្ពុជា[ម្នាក់]"[25]។ ពុំមានការយោងទៅដល់កិច្ចសម្ភាសន៍ណាមួយដែលបានធ្វើឡើងដោយលោក Hinton នៅក្នុងជើងទំព័រនៃសៀវភៅរបស់គាត់ទេ[26] ហើយកម្រឃើញមានការយោងជាក់លាក់ទៅនឹងអ្វីដែលបុគ្គលបាននិយាយប្រាប់គាត់ណាស់។

12. នៅក្នុងតុលាការ លោក Hinton បានផ្តល់សក្ខីកម្មថា ជាផ្នែកនៃកិច្ចស្រាវជ្រាវ រហស្សនាមត្រូវបានប្រើប្រាស់ ដើម្បីយោងទៅដល់មនុស្សដែលគាត់បាននិយាយជាមួយ ហើយថា ជាលទ្ធផលគាត់មិនអាចចាំឈ្មោះមនុស្សដែលគាត់បាននិយាយជាមួយទេ[27]។ នៅពេលសួរថាតើគាត់អាចផ្តល់ជូនអង្គជំនុំជម្រះ និងភាគីនូវអត្តសញ្ញាណរបស់អ្នកផ្តល់ព័ត៌មានគន្លឹះដែលផ្តល់ព័ត៌មានដល់គាត់ឈ្មោះ "ទិព្វ" បានឬទេ លោក Hinton បានឆ្លើយតបថា គាត់នឹងទៅពិនិត្យមើលកំណត់ត្រារបស់គាត់សិន ដើម្បីសម្រេចថាតើ ឈ្មោះនេះគួរបញ្ចេញឲ្យដឹងដែរឬទេ ហើយគាត់នឹងសួរទៅសាកលវិទ្យាល័យរបស់គាត់ថាតើគាត់អាចបញ្ចេញឈ្មោះបានទេ ទាក់ទិននឹង "ពិធីសារស្តីពីមនុស្ស" ដែលអនុវត្តចំពោះការស្រាវជ្រាវរបស់គាត់នោះ[28]។ គាត់ក៏បានលើកឡើងផងដែរទៅដល់ "ក្រដាសលេខ

---

ពិតសម្រាប់អ្នកនៅរស់រានមានជីវិតពីទួលស្លែង ដែលបានសរសេរអំពីបទពិសោធន៍របស់ខ្លួន ដោយប្រើឈ្មោះខ្លួនឯងផ្ទាល់ ជាបុគ្គលសាធារណៈសំខាន់ៗ និង កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ និងទាហានដែលមានឈ្មោះនៅក្នុងកិច្ចសម្ភាសន៍របស់ខ្ញុំ"។ *សូមមើល ឧទាហរណ៍* ឯកសារ **E3/3346**៖ "Chlat" លេខ ERN 00431658 (ភាសាអង់គ្លេស), លេខ ERN 00707459 (ភាសាបារាំង), "Khel" លេខ ERN 00431481 (ភាសាអង់គ្លេស) (ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ), "Neari" លេខ ERN 00431484 (ភាសាអង់គ្លេស) (ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ), "Teap" លេខ ERN 00431707 (ភាសាអង់គ្លេស) (ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ), "Lor" លេខ ERN 00431444 (ភាសាអង់គ្លេស) (ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ)។ *សូមមើល ផងដែរ* ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៥ បន្ទាត់ ១០ ដល់ ១៣។

[23] ឯកសារ **E3/3346** លេខ ERN 00431710-11 (ភាសាអង់គ្លេស)។ ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ។

[24] ឯកសារ **E3/3346** លេខ ERN 00431599 (ភាសាអង់គ្លេស)។ ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ។

[25] ឯកសារ **E3/3346** លេខ ERN 00431695 (ភាសាអង់គ្លេស)។ ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ។

[26] ឯកសារ **E3/3346** លេខ ERN 00431743-1767 (ភាសាអង់គ្លេស)។ ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ។

[27] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៥ បន្ទាត់ ៩ ដល់ ១១។

[28] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៥ បន្ទាត់ ៩ ដល់ ១៤, ទំព័រ ១៦ បន្ទាត់ ៧ ដល់ ៨។

កូដ” ដែលអាចអនុញ្ញាតឲ្យគាត់កំណត់ឈ្មោះមនុស្សដែលគាត់បាននិយាយជាមួយ[29]។

13. លោក Hinton មិនបានយកកំណត់ត្រា ប្រតិចារឹក ឬសម្ភារៈនានាដែលគាត់បានប្រើប្រាស់ នៅក្នុងការនិពន្ធសៀវភៅរបស់គាត់ មក អ.វ.ត.ក នៅពេលគាត់មកបង្ហាញខ្លួនទេ ហេតុនេះ គាត់មិនអាចឆ្លើយតបទៅនឹងសំណួររបស់ភាគីទាក់ទិននឹងអត្តសញ្ញាណមនុស្សដែលគាត់បានសម្ភាសទេ[30]។

## III. ច្បាប់ជាធរមាន

14. វិធាន ៩៣ នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យមានកិច្ចស៊ើបសួរបន្ថែម គ្រប់ពេលនៃដំណើរការកិច្ចនីតិវិធី ក្នុងករណីអង្គជំនុំជម្រះយល់ឃើញថាចាំបាច់[31]។ ការស៊ើបអង្កេតអាចរួមមាន *ក្នុងចំណោមនោះ* ការស្ដាប់ចម្លើយសាក្សី ធ្វើការឆែកឆេរ ឬ ចាប់យកភ័ស្ដុតាង ឬបង្គាប់ឲ្យធ្វើកោសលវិច័យ។ ការស៊ើបអង្កេតបន្ថែមបែបនេះត្រូវធ្វើឡើងក្រោមលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌអនុវត្តរបស់សហចៅក្រមស៊ើបអង្កេត[32]។

15. លក្ខណវិនិច្ឆ័យស្ដីពីភាពចាំបាច់នៅក្នុងវិធាន ៩៣ មានន័យថា ការស៊ើបអង្កេតត្រូវតែធ្វើឡើងដើម្បីជាប្រយោជន៍នៃយុត្តិធម៌[33]។ ម្យ៉ាងវិញទៀត ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិនិត្យក្នុងបរិបទនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក រួមទាំង សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស[34]។

16. នៅគ្រប់ពេលវេលាទាំងអស់ អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថា ការជំនុំជម្រះត្រូវមានភាពយុត្តិធម៌ និងឆាប់រហ័ស ហើយត្រូវធ្វើឡើងដោយគោរពសិទ្ធិជនជាប់ចោទឲ្យបានពេញលេញ និង

---

[29] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៦ បន្ទាត់ ៨។

[30] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៥ បន្ទាត់ ៩ ដល់ ១១, ទំព័រ ១៦ បន្ទាត់ ៦ ដល់ ៨។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ១០ បន្ទាត់ ២ ដល់ ៤។

[31] វិធាន ៩៣(១) នៃវិធានផ្ទៃក្នុង។

[32] វិធាន ៩៣(២) នៃវិធានផ្ទៃក្នុង។

[33] ឯកសារ E294/1 “សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភ័ស្ដុតាងថ្មី ឲ្យចាប់ផ្ដើមការស៊ើបអង្កេត និងឲ្យកោះហៅលោក ROB LEMKIN” ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ ១១។

[34] ឯកសារ E294/1 “សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភ័ស្ដុតាងថ្មី ឲ្យចាប់ផ្ដើមការស៊ើបអង្កេត និងឲ្យកោះហៅលោក ROB LEMKIN” ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ ១១។

ការពារជនរងគ្រោះ និងសាក្សី[35]។ ជាពិសេស ប្រធានអង្គជំនុំជម្រះត្រូវធានានូវការអនុវត្តសិទ្ធិការពារក្តីដោយសេរី អនុលោមតាមវិធាន ៨៥(១) នៃវិធានផ្ទៃក្នុង។

17. គ្រប់ជនជាប់ចោទនៅចំពោះមុខតុលាការនេះមានសិទ្ធិទទួលបានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន[36] ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភ័ស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុក[37]។ អង្គជំនុំជម្រះសាលាដំបូងមានភារកិច្ចការពារសិទ្ធិទាំងនេះ និងធ្វើយ៉ាងណាឲ្យការជំនុំ ជម្រះដំណើរការទៅដោយយុត្តិធម៌ និងឆាប់រហ័ស ដោយត្រូវគោរពពេញលេញលើសិទ្ធិរបស់ជន ជាប់ចោទ និងការពារដល់ជនរងគ្រោះ និងសាក្សីផងដែរ[38]។ ជាពិសេស ប្រធានអង្គជំនុំជម្រះត្រូវ ធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តដោយសេរី[39]។

18. វិធាន ៣១ នៃវិធានផ្ទៃក្នុង បញ្ញត្តិអំពីការតែងតាំងអ្នកជំនាញដោយ អ.វ.ត.ក។ វិធាននេះពុំមានបទប្បញ្ញត្តិចែងទាក់ទងនឹងប្រភពដែលអ្នកជំនាញសំអាងនៅក្នុងរបាយការណ៍/ភ័ស្តុតាងរបស់គេនោះទេ។

19. មាត្រា ៣៣ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ចែងថា ប្រសិនបើនីតិវិធី អ.វ.ត.ក ជាធរមានមិនមានចែងអំពីបញ្ហាជាក់លាក់ណាមួយ ឬប្រសិនបើមានភាពពុំច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្ត ឬ ប្រសិនបើមានបញ្ហាចោទទាក់ទិននឹងភាពស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ តុលាការអាចមើលការណែនាំនៅក្នុងវិធាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិបាន។ ដូច្នេះ ការអនុវត្ត និងយុត្តិសាស្ត្រនៃសាលាក្តីអន្តរជាតិផ្សេងទៀតផ្តល់ជាការណែនាំដ៏សំខាន់។

20. សាលាក្តី ICTY បានសម្រេចថា "តុលាការរំពឹងថា សាក្សីជំនាញនឹងផ្តល់យោបល់ជំនាញរបស់

---

[35] មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[36] មាត្រា ៣៥(ខ) ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អ.វ.ត.ក")។

[37] មាត្រា ៣៥(ង) ថ្មី នៃច្បាប់ អ.វ.ត.ក។

[38] មាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក។

[39] វិធាន ៨៥ នៃវិធានផ្ទៃក្នុង។

គាត់ដោយមានតម្លាភាពពេញលេញអំពីអង្គហេតុដែលបានរកឃើញ ឬត្រូវបានសន្មត ដែលអ្នកជំនាញបានសំអាង និងវិធីសាស្ត្រដែលបានប្រើនៅពេលប្រើប្រាស់ការយល់ដឹង បទពិសោធន៍ ឬជំនាញរបស់ខ្លួន ដើម្បីបង្កើតយោបល់ជំនាញរបស់គាត់[40]"។ ដូច្នេះ ត្រូវមានព័ត៌មានគ្រប់គ្រាន់អំពីប្រភពដែលបានប្រើប្រាស់ដើម្បីគាំទ្រការលើកឡើងរបស់អ្នកជំនាញ[41]។ ជាពិសេស ប្រភពដែលបានប្រើប្រាស់ដោយសាក្សីជំនាញត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ និងអាចពិនិត្យមើលបាន[42] ដើម្បីអនុញ្ញាតឲ្យភាគីម្ខាងទៀតជំទាស់មូលដ្ឋានដែលសាក្សីជំនាញបានទាញការសន្និដ្ឋាន ឬ វិធីសាស្ត្ររបស់សាក្សីអ្នកជំនាញ[43]។

[40] សាលាក្តី ICTY៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* IT-98-29-T សេចក្តីសម្រេចទាក់ទងនឹងសាក្សីជំនាញ Ewa Tabeau និង Richard Philipps ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០២ ទំព័រ ២។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឲ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសលវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* IT-06-90-T សេចក្តីសម្រេចលើការដាក់បង្ហាញសម្ភារះរបស់អ្នកជំនាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១០។

[41] សាលាក្តី ICTY៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić & Župljanin* សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយក Hanson របស់ Dorothea ជាសាក្សីជំនាញ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង D. Milošević*, IT-98-29/1-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍កោសលវិច័យរបស់ Robert Donia ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić*, IT-95-5/18-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំដកចេញរបាយការណ៍កោសលវិច័យរបស់ Kosta Čavoški ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២២។

[42] សាលាក្តី ICTY៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić & Župljanin* សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយក Hanson របស់ Dorothea ជាសាក្សីជំនាញ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង D. Milošević*, IT-98-29/1-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍កោសលវិច័យរបស់ Robert Donia ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić*, IT-95-5/18-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំដកចេញរបាយការណ៍កោសលវិច័យរបស់ Kosta Čavoški ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២២។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឲ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសលវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* IT-06-90-T សេចក្តីសម្រេចលើការដាក់បង្ហាញសម្ភារះរបស់អ្នកជំនាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១០។

[43] សាលាក្តី ICTY៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić & Župljanin* សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយក Hanson របស់ Dorothea ជាសាក្សីជំនាញ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង D. Milošević*, IT-98-29/1-T សេចក្តីសម្រេចលើការទទួលយករបាយ

21. ប្រសិនបើភាគី និងអង្គជំនុំជម្រះសាលាដំបូង មិនអាចវាយតម្លៃទៅលើតម្លៃជាភស្តុតាងនៃរបាយការណ៍របស់អ្នកជំនាញដែលបានស្នើឡើង ដោយសារកង្វះតម្លាភាព របាយការណ៍នេះអាចថាមិនត្រូវទទួលយកមកធ្វើជាភស្តុតាង ឬក៏ថា អង្គជំនុំជម្រះអាចផ្តល់ទម្ងន់តិចតួចប៉ុណ្ណោះលើរបាយការណ៍នោះ[44]។ ដោយសារមិនមានការយោងច្បាស់លាស់ ឬប្រភពដែលអាចពិនិត្យមើលបាន សាលាក្តី ICTY នឹងមិនចាត់ទុកការលើកឡើង ឬរបាយការណ៍នេះថាជាមតិយោបល់របស់*អ្នកជំនាញ* នោះទេ ប៉ុន្តែចាត់ទុកជាមតិយោបល់*ផ្ទាល់ខ្លួន*របស់សាក្សី ហើយផ្តល់ទម្ងន់ទៅតាមនោះ[45]។ អាចនិយាយម្យ៉ាងទៀតថា ផ្នែកនៃរបាយការណ៍ និង/ឬសក្ខីកម្មដែលមានប្រភពមិនច្បាស់លាស់ ឬក្នុងករណីដែលភាគីមិនមានឱកាសពិនិត្យ ឬតវ៉ាសាក្សីដែលបានផ្តល់ព័ត៌មាន នឹងត្រូវបានផ្តល់ទម្ងន់តិចតួចប៉ុណ្ណោះ ប្រសិនបើផ្តល់ឲ្យនោះ[46]។

22. ជាលទ្ធផល វាជាការអនុវត្តមួយច្បាស់លាស់នៅសាលាក្តី ICTY ដែលថា ភាគីដែលកោះហៅអ្នក

---

ការណ៍កោសលវិច័យរបស់ Robert Donia ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić*, IT-95-5/18-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំដកចេញរបាយការណ៍កោសលវិច័យរបស់ Kosta Čavoški ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២២។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឲ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសលវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* IT-06-90-T សេចក្តីសម្រេចលើការដាក់បង្ហាញសម្ភារៈរបស់អ្នកជំនាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១០។

[44] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* IT-06-90-T សេចក្តីសម្រេចលើការដាក់បង្ហាញសម្ភារៈរបស់អ្នកជំនាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១០។

[45] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង D. Milošević*, IT-98-29/1-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍កោសលវិច័យរបស់ Robert Donia ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Martić*, IT-95-11-T សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលើរបាយការណ៍កោសលវិច័យរបស់សាស្ត្រាចារ្យ អនុលោមតាមវិធាន ៩៤*ស្ទួន* ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឲ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសលវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić*, IT-95-5/18-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំដកចេញរបាយការណ៍កោសលវិច័យរបស់ Kosta Čavoški ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២២។

[46] សាលាក្តី ICTY៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឲ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសលវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។

ជំនាញបង្ហាញរបាយការណ៍អ្នកជំនាញ រួមជាមួយនឹងប្រភពដែលបានប្រើប្រាស់សម្រាប់របាយការណ៍នោះ[47]។ តុលាការ ICC បានក៏បានអនុវត្តតាមការអនុវត្តនេះដែរ[48]។

23. លើសពីនេះទៀត តុលាការ ICC បានសម្រេចថា បញ្ហាទាំងឡាយជុំវិញប្រភពដែលបានប្រើប្រាស់ ឬ ការលើកយោង វចនាសម្ព័ន្ធ ឬវិធីសាស្ត្រនៃរបាយការណ៍ គឺជាបញ្ហាដែលអាចលើកឡើងនៅក្នុងអំឡុងពេលសួរដេញដោល និងត្រូវយកមកពិចារណានៅពេលវាយតម្លៃលើទម្ងន់នៃរបាយការណ៍នេះ ប្រសិនបើត្រូវទទួលយកនោះ[49]។

## IV. ឧទ្ទិករណ៍

24. មកទល់ពេលនេះ ភាគី និងអង្គជំនុំជម្រះសាលាដំបូង ពុំមានព័ត៌មានខាងក្រោមទាក់ទងនឹងភ័ស្តុតាងរបស់ Hinton នោះឡើយ៖

(ក) អត្តសញ្ញាណមនុស្សដែលគាត់បានសម្ភាសជាផ្លូវការ និងខ្លឹមសារនៃកិច្ចសម្ភាសន៍

[47] *សូមមើល ឧ.* សាលាក្តី ICTY៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Simatović*, IT-03-69-PT សេចក្តីសន្និដ្ឋានរបស់អយ្យការលើរបាយការណ៍កោសលវិច័យរបស់ Christian Nielsen អនុលោមតាមវិធាន ៩៤*ស្ទួន* ជាមួយនឹងឧបសម្ព័ន្ធ ក និង ខ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌ ១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić*, IT-95-5/18-T ញត្តិរបស់អយ្យការសុំទទួលយកភ័ស្តុតាងរបស់អ្នកជំនាញចំនួន ៨ នាក់ អនុលោមតាមវិធាន ៩៤*ស្ទួន* និងវិធាន ៩២*ស្ទួន* ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ១៧។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mladić*, IT-09-92-T សេចក្តីជូនដំណឹងរបស់អយ្យការលើការដាក់បង្ហាញរបាយការណ៍កោសលវិច័យរបស់ Andras Riedlmayer (RM 618) អនុលោមតាមវិធាន ៩៤*ស្ទួន* និងញត្តិសុំកែប្រែបញ្ជីវត្ថុតាងយោងតាមវិធាន ៦៥*ស្ទួនពីរ* ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៣ កថាខណ្ឌ ៧។

[48] តុលាការ ICC៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba និងអ្នកផ្សេងទៀត* ICC-01/05-01/13 ចម្លើយតបរបស់អយ្យការទៅនឹងសំណើរួមរបស់មេធាវីការពារក្តីអនុលោតាមបទប្បញ្ញត្តិ ៣៥ នៃបទប្បញ្ញត្តិរបស់តុលាការក្នុងការព្យួរសេចក្តីជូនដំណឹងទាក់ទងនឹងសាក្សីជំនាញ (N. ICC-01/05-01/13-1242) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ៥។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba និងអ្នកផ្សេងទៀត* ICC-01/05-01/13 សេចក្តីសម្រេចលើសំណើរួមរបស់មេធាវីការពារក្តីអនុលោតាមបទប្បញ្ញត្តិ ៣៥ នៃបទប្បញ្ញត្តិរបស់តុលាការក្នុងការព្យួរសេចក្តីជូនដំណឹងទាក់ទងនឹងសាក្សីជំនាញ (N. ICC-01/05-01/13-1280) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ១១។

[49] តុលាការ ICC៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntaganda*, ICC-01/04-02/06 សេចក្តីសម្រេចលើចម្លើយតបរបស់អយ្យការទៅនឹងការជំទាស់បឋមលើសាក្សីជំនាញរបស់អយ្យការ (N. ICC-01/04-02/06-1159) ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ១៦។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ruto & Sang*, ICC-01/09-01/11 សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តី Sang សុំដកចេញរបាយការណ៍ជំនាញរបស់លោក Hervé Maupeu (N. ICC-01/09-01/11-844) ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ កថាខណ្ឌ ២៧។

ទាំងនោះ។

(ខ) អត្តសញ្ញាណមនុស្សដែលលោក Hinton ហៅថា "ការសន្ទនាធម្មតា" ឬ ខ្លឹមសារនៃការសន្ទនាទាំងនេះ ហើយ

(គ) ខ្លឹមសារ និងចម្លើយតបនៃការអង្កេតដែលលោក Hinton បានធ្វើឡើងនៅចន្លោះឆ្នាំ១៩៩៤ ដល់ ឆ្នាំ១៩៩៥។

25. មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមានការស៊ើបអង្កេតមួយ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដើម្បីឱ្យលោក Hinton ផ្តល់ជូនភាគីនូវឯកសារមួយចំនួនដែលសំខាន់ចំពោះការវាយតម្លៃលើភាពអាចទុកចិត្តបាននៃសៀវភៅ និងសក្ខីកម្មរបស់គាត់ ព្រមទាំងដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌។ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់វិធាន ៩៣ នៅក្នុងសំណុំរឿង ០០២/០១ ដើម្បីស្នើសុំឱ្យផ្តល់ព័ត៌មានពីសាក្សីជំនាញ TCE-33 (បច្ចុប្បន្ន សាក្សី 2-TCE-87)[50] ហើយមេធាវីការពារក្តីសន្និដ្ឋានថា វិធានការដូចគ្នានេះគួរធ្វើឡើងនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ។

## ក. ប្រភេទនៃសម្ភារៈដែលបានស្នើសុំ

26. មេធាវីការពារក្តីស្នើសុំឱ្យផ្តល់ឯកសារចំនួនបួនប្រភេទ៖

(ក) ការអង្កេតដែលលោក Hinton បានធ្វើឡើងនៅភូមិពោធិ៍ក្នុងឆ្នាំ ១៩៩៤ រួមទាំងចម្លើយតបដែលបានធ្វើឡើងនៅក្នុងនោះដោយអ្នកចូលរួមប្រមាណពី ៩៥ ទៅ ១០០ នាក់នោះ។

(ខ) ខ្សែអាត់សម្លេងនៃកិច្ចសម្ភាសន៍របស់លោក Hinton ជាមួយនឹង "អ្នកផ្តល់ព័ត៌មានសំខាន់ៗ" របស់គាត់ ហើយនឹងខ្សែអាត់សម្លេងផ្សេងទៀតដែលលោក Hinton បានថតនៅពេលសម្ភាសបុគ្គលផ្សេងៗសម្រាប់សរសេរសៀវភៅរបស់គាត់ ព្រមទាំងប្រតិចារឹកខ្មែរនៃកិច្ចសម្ភាសន៍ និងសំណៅបកប្រែជាភាសាអង់គ្លេស បើសិនជាមាន។

(គ) កំណត់ត្រារបស់លោក Hinton ដែលបានធ្វើឡើងតាមរយៈ "ការសង្កេតរបស់អ្នកចូលរួម" និងកំណត់ត្រាជាលាយលក្ខណ៍អក្សរផ្សេងទៀតនៃកិច្ចសម្ភាសន៍ "ធម្មតា" និង

---

[50] ឯកសារ E169 "សំណើសុំព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសង្ខេបដែលអ្នកជំនាញ TCE-33 បានរៀបចំ" ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២។

(ឃ) "ក្រដាសលេខកូដ" ដែលលោក Hinton បានយោងនៅក្នុងពេលគាត់ផ្តល់សក្ខីកម្ម[51]។

## ខ. បញ្ហាបឋម

27. មេធាវីការពារក្តីសូមបញ្ជាក់ពីដំបូងថា មេធាវីការពារក្តីមិនមែនស្នើសុំឯកសារទាំងនោះឲ្យដាក់បញ្ចូលជាភស្តុតាងនោះទេ។ មេធាវីការពារក្តីសន្និដ្ឋានថា ការទទួលយកនៅពេលនេះគឺជាការអនុវត្តលឿនពេក ដោយពុំបានដឹងថាតើវាជាឯកសារអ្វីខ្លះ ឬខ្លឹមសាររបស់វាជាអ្វីនៅឡើយនោះ[52]។ នៅក្នុងដំណាក់កាលនេះ អ្វីដែលមេធាវីការពារក្តីស្នើសុំនោះគឺថាត្រូវផ្តល់សំណៅថតចម្លងនៃឯកសារនានា ដើម្បីវាយតម្លៃទីមួយទៅលើ ភាពត្រឹមត្រូវនៃការអះអាងរបស់លោក Hinton និងទីពីរ ទៅលើថាតើ ឯកសារណាខ្លះក្នុងចំណោមឯកសារទាំងនោះ គួរដាក់បញ្ចូលជាភស្តុតាងអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះ។

28. មេធាវីការពារក្តីមិនអាចដាក់សំណើសុំបច្ចុប្បន្ននេះឲ្យបានលឿនជាងនេះទេ ដោយសារមេធាវីសង្ឃឹមថានឹងយកព័ត៌មានទាក់ទងនឹងអត្តសញ្ញានៃប្រភពរបស់លោក Hinton នៅក្នុងអំឡុងពេលការដេញដោលលើរូបគាត់នៅក្នុងតុលាការ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញហើយ ព័ត៌មានបែបនេះនៅទីបំផុតមិនអាចទទួលបាន ដោយសារ លោក Hinton ពុំអាចផ្តល់ព័ត៌មានជាក់លាក់ទាក់ទងនឹងប្រភពរបស់គាត់ដូចបានពិពណ៌នានៅក្នុងកថាខណ្ឌ ១១ និង១៣ ខាងលើ និង ៣១ ដល់ ៣៤ ខាងក្រោម។

## គ. សម្ភារៈដែលបានស្នើឡើងគឺជាការចាំបាច់ក្នុងការវាយតម្លៃទៅលើទម្ងន់ដែលផ្តល់ដល់សៀវភៅរបស់លោក Hinton និងសក្ខីកម្មរបស់គាត់ និងក្នុងការបង្ហាញការពិត

### *(១) ភស្តុតាងរបស់លោក Hinton ភាគច្រើនផ្អែកទៅលើការងារចុះដល់ទីកន្លែង/កិច្ចសម្ភាសន៍របស់គាត់*

29. ភាគច្រើន ជំនាញរបស់លោក Hinton បានមកពីការងារចុះដល់ទីកន្លែងដែលគាត់បានធ្វើនៅ

---

[51] *សូមមើលខាងលើ* កថាខណ្ឌ ១២។

[52] មេធាវីការពារក្តីកត់សម្គាល់ឃើញថា ខុសពីពេលដែលខ្លួនបានស្នើសុំប្រមូល និងទទួលយកសៀវភៅរបស់សាក្សី ញៀម អេន មកដាក់បញ្ចូលនៅក្នុងភស្តុតាងនៅក្នុងកាលៈទេសៈបច្ចុប្បន្ន មេធាវីការពារក្តីមិនបានដឹងអំពីលក្ខណៈ និងខ្លឹមសារនៃឯកសារដែលបានលើកឡើងនេះទេ ហេតុដូច្នេះ មិនអាចបង្ហាញជំហរថាតើឯកសារទាំងនោះគួរទទួលយកមកដាក់បញ្ចូលនៅក្នុងភស្តុតាងឬក៏អត់នោះឡើយ។

ប្រទេសកម្ពុជានៅពេលគាត់រៀបចំនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់នៅឆ្នាំ ១៩៩២ និង នៅឆ្នាំ ១៩៩៤-១៩៩៥ និងពីការស្រាវជ្រាវផ្សេងៗទៀត ដែលគាត់បានធ្វើមុនឆ្នាំ ២០០២ នៅពេលគាត់ធ្វើបច្ចុប្បន្នភាពនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ ដើម្បីបោះពុម្ពសៀវភៅគាត់ដែលមានចំណងជើងថា *ហេតុអ្វីបានជាពួកគេសម្លាប់?*

30. លោក Hinton បានផ្តល់សក្ខីកម្មថា "ភាគច្រើន" នៃព័ត៌មានដែលមាននៅក្នុងសៀវភៅរបស់គាត់ បានមកពីការស្រាវជ្រាវនៅខេត្តកំពង់ចាម និងនៅស្រុកកំពង់សៀម ក្នុងតំបន់ ៤១[53]។ ជាពិសេស គាត់បានផ្តល់សក្ខីកម្មថា ការរកឃើញរបស់គាត់ភាគច្រើនទាក់ទិននឹងអ្វីដែលបានកើតឡើងចំពោះប្រជាជននៅកំពង់ចាម ផ្អែកលើកិច្ចសម្ភាសន៍នានាដែលគាត់បានធ្វើ[54]។

31. ហេតុនេះ ភាគច្រើនលើសលប់នៃអំណះអំណាងរបស់លោក Hinton ពិតជាផ្អែកលើកិច្ចសម្ភាសន៍នានាដែលគាត់បានធ្វើមុនឆ្នាំ ២០០២ ហើយ លទ្ធភាពពិនិត្យមើលកិច្ចសម្ភាសន៍ទាំងនោះគឺជាចំណុចសំខាន់ក្នុងការវាយតម្លៃលើភ័ស្តុតាងរបស់គាត់។

### *(២) លោក Hinton ពុំបានផ្តល់ចម្លើយជាក់លាក់ នៅពេលគាត់ត្រូវបានសាកសួរពីប្រភពរបស់គាត់*

32. នៅក្នុងសៀវភៅរបស់គាត់ និងនៅពេលផ្តល់សក្ខីកម្ម លោក Hinton បានផ្តល់ភ័ស្តុតាងទាក់ទិននឹងការចោទប្រកាន់ពីគោលនយោបាយ និងសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសទាក់ទិននឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាម។ ដូចបានលើកឡើងយ៉ាងច្បាស់នៅក្នុងយុត្តិសាស្ត្រដែលបានបង្កើតឡើងជាអន្តរជាតិ អ្នកជំនាញ**ត្រូវ**ផ្តល់ព័ត៌មានគ្រប់គ្រាន់ទាក់ទិននឹងវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ និងប្រភពដែលគាត់យកមកសំអាងដើម្បីធ្វើសេចក្តីសន្និដ្ឋាន[55]។

33. នៅក្នុងករណីនេះ លោក Hinton ពុំបានផ្តល់ប្រភពជាក់លាក់ និងប្រភពជាបុគ្គល សម្រាប់គាំទ្រដល់សេចក្តីសន្និដ្ឋានជាច្រើនដែលគាត់បានធ្វើ ទោះនៅក្នុងសៀវភៅ ឬក្នុងអំឡុងពេលគាត់ផ្តល់សក្ខីកម្មក្តី។ នៅក្នុងឱកាសជាច្រើន នៅពេលគាត់ត្រូវបានសាកសួរអំពីមូលដ្ឋានសម្រាប់អំណះ

---

[53] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៦៩ បន្ទាត់ ១២ ដល់ ទំព័រ ៧១ បន្ទាត់ ៣។

[54] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៧៦ បន្ទាត់ ២៣ ដល់ ទំព័រ ៧៦ បន្ទាត់ ២, ទំព័រ ៧៦ បន្ទាត់ ១៨ ដល់ ១៩។

[55] *សូមមើល ខាងលើ* ផ្អែកច្បាប់ជាធរមាន កថាខណ្ឌ ២០ ដល់ ១១ *គូសបញ្ជាក់បន្ថែម*។

អំណាងរបស់គាត់ លោក Hinton បានឆ្លើយថា គាត់មិនអាចផ្តល់ចម្លើយជាក់លាក់បានទេ ដោយសារគាត់ពុំមានសម្ភារៈ/ឯកសារស្រាវជ្រាវមកជាមួយ[56] ឬបានយោងជាទូទៅដល់“ឯកសារដែលមានស្រាប់” “កិច្ចសម្ភាសន៍ជាមួយសាក្សី” ឬ “ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ”[57]។

34. ជាងនេះទៀត លោក Hinton ពិតជាមានការភាន់ច្រឡំនៅក្នុងតុលាការ ពាក់ព័ន្ធនឹងប្រភពដែលធ្វើឲ្យគាត់ដឹង ដោយសារគាត់បានយោងជាច្រើនដងទៅលើការជំនុំជម្រះ *ឌុច* ព្រមទាំងឯកសារផ្សេងៗទៀតដែលមានក្រោយពេលបោះពុម្ពសៀវភៅរបស់គាត់[58]។ គាត់ក៏បានលើកឡើងចំណុចមួយចំនួនថា ចុងក្រោយ ភ័ស្តុតាងនៅចំពោះមុខតុលាការបានបញ្ជាក់ ឬនឹងបញ្ជាក់អំពីការយល់ឃើញរបស់គាត់[59]។ នៅពេលសួរឲ្យអំពីការផ្ទៀងផ្ទាត់ប្រភពព័ត៌មានរបស់ខ្លួន លោក Hinton បានឆ្លើយថា “[ដូច្នេះ] ខ្ញុំគិតថា ភាគច្រើននៃអ្វីដែលខ្ញុំបាននិយាយ ដោយមិនគិតពីប្រភព គឺមាននៅក្នុងកំណត់ហេតុនៃកិច្ចសម្ភាសន៍ផ្សេងៗដែលបានធ្វើឡើយ។ នោះគឺជាកំណត់ហេតុតុលាការ

---

[56] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៥ បន្ទាត់ ១១ ដល់ ១៤, ទំព័រ ១៦ ទំព័រ ៦ ដល់ ៩, ទំព័រ ១៨ បន្ទាត់ ២៤, ទំព័រ ៤០ បន្ទាត់ ១១ ដល់ ១២។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ១០ បន្ទាត់ ១៧ ដល់ ១៨។

[57] *សូមមើល ឧទាហរណ៍* ប្រតិចារឹកសវនាការ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/401.1**) ទំព័រ ៤៤ បន្ទាត់ ៩ ដល់ ១១ (“យើងមានចំណុចមួយទៀតដែលខ្ញុំសរសេរ ហើយរៀបរាប់អំពីស្ថានភាពនៅក្នុងស្រុកកំពង់សៀម។ លោកក៏អាចមើលទៅលើឯកសារខ្មែរក្រហម ការបោះពុម្ពផ្សាយជាឯកសារផ្សេងៗ គឺថាវាមានលើកឡើងដូចចំណុចនេះមែន”)។ *ដូចយោងខាងលើ* នៅត្រង់ទំព័រ ៧០ បន្ទាត់ ២ ដល់ ៣ (“ភ័ស្តុតាងជាច្រើនរួមទាំងកំណត់ត្រារបស់អ្នកសួរចម្លើយ”)។ *ដូចយោងខាងលើ* នៅត្រង់ទំព័រ ៧៥ បន្ទាត់ ១ (“មានភ័ស្តុតាងច្បាស់ថា [បទចម្រៀងគោរពទង់ជាតិ] ត្រូវបានចាក់គ្រប់ពេល”)។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ៧០ បន្ទាត់ ១៨ ដល់ ២១ (“មានភ័ស្តុតាងជាច្រើន”)។

[58] *សូមមើល ឧទាហរណ៍* ប្រតិចារឹកសវនាការ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/401.1**) ទំព័រ ៤៣ ទំព័រ ២ ដល់ ៤, ទំព័រ ៤៤ បន្ទាត់ ១១ ដល់ ១២, ទំព័រ ៤៤ បន្ទាត់ ២២ ដល់ ២៤, ទំព័រ ៦៥ បន្ទាត់ ៨ ដល់ ៩, ទំព័រ ៧០ បន្ទាត់ ១៦ ដល់ ១៨, ទំព័រ ៧៦ បន្ទាត់ ៩ ដល់ ១១។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ៣៨ បន្ទាត់ ១ ដល់ ៣។

[59] *សូមមើល ឧទាហរណ៍* ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ៧៣ បន្ទាត់ ១៩ ដល់ ២០, ទំព័រ ៧៣ ទំព័រ ២៤ ដល់ ២៥។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ១២ បន្ទាត់ ៨ ដល់ ១០។

នេះ"[60]។ ច្បាស់ណាស់ ប្រភពទាំងនោះមិនអាចរកបាននៅពេលលោក Hinton និពន្ធសៀវភៅរបស់គាត់ ហេតុនេះ មិនអាចថាបង្ហាញ "ភស្តុតាង" ពីជំនាញរបស់គាត់ឡើយ។ ចំណុចសំខាន់ចុងក្រោយ លោក Hinton មិនបានផ្តល់ការយោងជាក់លាក់ទៅបុគ្គល ឬឯកសារនានាដែលត្រូវបានចោទប្រកាន់ ដែល "បានបញ្ជាក់" ពីការយល់ឃើញរបស់គាត់ទេ។

35. សរុបមក ទោះបីនៅក្នុងសៀវភៅរបស់គាត់ ឬក្នុងអំឡុងពេលគាត់ផ្តល់សក្ខីកម្មក៏ដោយ លោក Hinton មិនអាចបង្ហាញប្រភពព័ត៌មានជាមូលដ្ឋានណាមួយច្បាស់លាស់ ដើម្បីឲ្យមេធាវីការពារក្តី ឬអង្គជំនុំជម្រះសាលាដំបូង អះអាងបានពីភាពត្រឹមត្រូវនៃការអះអាងរបស់គាត់ទេ។ ហេតុនេះ ពុំមានព័ត៌មានអ្វីទាល់តែសោះ ទាក់ទិននឹង យថាភាព និងភាពជឿជាក់បាននៃភ័ស្តុតាងរបស់លោក Hinton។ ជាការពិត មកដល់ពេលនេះ ពុំមានភ័ស្តុតាងដែលថា លោក Hinton ពិតជាបានធ្វើការស្រាវជ្រាវដល់ទីកន្លែងនៅប្រទេសកម្ពុជា ឬពិតជាបានធ្វើការសម្ភាសន៍បុគ្គលនានា ក្រៅពីការលើកឡើងរបស់គាត់ផ្តល់នោះទេ។

### *(៣) ការពិនិត្យមើលប្រភពព័ត៌មានរបស់លោក Hinton ជាការចាំបាច់ ដើម្បីអះអាងពីភាពត្រឹមត្រូវនៃការអះអាងរបស់គាត់*

36. ការទទួលបានប្រភពព័ត៌មានដែលលោក Hinton បានយកមកប្រើប្រាស់ ជាការសំខាន់យ៉ាងខ្លាំង ដោយសារគាត់បានផ្តល់សក្ខីកម្មជាច្រើនលើកច្រើនដងថា បញ្ហាសំខាន់របស់គាត់គឺដើម្បី "តំណាងប្រជាជនដែលរស់នៅក្នុងស្រុកហ្នឹង"[61] ហើយថា គាត់បានធ្វើការស្រាវជ្រាវទូទៅ និងមិនបានផ្តោតទៅលើការប្រព្រឹត្តិចំពោះក្រុមជនជាតិភាគតិចទេ[62]។ លោក Hinton បានផ្តល់សក្ខីកម្មថា គាត់បាននិយាយជាមួយមនុស្ស"ប្រាំមួយនាក់"ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាម[63]។ ទោះជាយ៉ាងនេះក្តី ភ័ស្តុតាងរបស់លោក Hinton ទៅលើប្រធានបទស្តីពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាម ត្រូវបានចាត់ទុកថាជាភ័ស្តុតាងរបស់ "អ្នកជំនាញ"។

---

[60] ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៩ បន្ទាត់ ៣ ដល់ ៥។

[61] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ៧៣ បន្ទាត់ ១៣ ដល់ ១៤។

[62] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៧ បន្ទាត់ ៨ ដល់ ១០។

[63] *សូមមើល ខាងលើ* កថាខណ្ឌ ៨។

37. ដោយគ្មានព័ត៌មានពាក់ព័ន្ធនឹងប្រភពព័ត៌មានជាក់លាក់ដែលលោក Hinton បានយកមកសំអាងសម្រាប់ការអះអាងជាក់លាក់នីមួយៗដែលគាត់មាន ហើយដោយគ្មានឯកសារជាមូលដ្ឋានដែលលោក Hinton បានប្រើប្រាស់ដើម្បីនិពន្ធសៀវភៅរបស់គាត់ មេធាវីការពារក្ដីពិតជាត្រូវបានរារាំងមិនឱ្យជំទាស់ទៅនឹងមូលដ្ឋាន ដែលអាចមាន ដែលលោក Hinton យកមកសំអាងក្នុងការធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន។ ចំណុចនេះរំលោភលើសិទ្ធិរបស់ នួន ជា ក្នុងការជំទាស់ទៅនឹងភ័ស្តុតាង និងសិទ្ធិរបស់គាត់ក្នុងការបង្ហាញភ័ស្តុតាង[64]។ មេធាវីការពារក្ដីពិតជាត្រូវបានរារាំងមិនឱ្យជំទាស់ឱ្យបានត្រឹមត្រូវទៅនឹងភ័ស្តុតាងរបស់លោក Hinton និងមិនឱ្យបង្ហាញភ័ស្តុតាងនានា ឧទាហរណ៍ ទាក់ទិននឹងភាពជឿជាក់បានរបស់បុគ្គលដែលលោក Hinton បាននិយាយជាមួយ។ មេធាវីការពារក្ដីក៏ត្រូវបានរារាំងមិនឱ្យបង្ហាញភ័ស្តុតាងដែលជំទាស់ទៅនឹងការលើកឡើងរបស់ពួកគេ ដោយសារមេធាវីការពារក្ដីមិនដឹងថា "អ្នកណាជាអ្នកនិយាយ និងនិយាយពីអ្វី" ទេ។

38. លោក Hinton ខ្លួនឯងបានលើកឡើងនៅក្នុងកិច្ចសម្ភាសន៍មួយនៅឆ្នាំ ២០១៣ ថា ការផ្ទៀងផ្ទាត់ពីភាពជឿជាក់បាននៃប្រភពព័ត៌មានគឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គនានាដែលនរវិទូជួបប្រទះ[65]។ ចំណុចនេះនាំឱ្យមេធាវីការពារក្ដីគិតថា អាចថា ចម្លើយមួយចំនួនដែលលោក Hinton បានផ្ដល់នៅក្នុងតុលាការអាចពុំមានមូលដ្ឋាន ឬពុំត្រឹមត្រូវ។ ក៏ប៉ុន្តែ មេធាវីការពារក្ដីមិនអាចកំណត់លើករណីនេះ ដោយមិនបានដឹងពីអត្តសញ្ញាណរបស់បុគ្គលដែលលោក Hinton សំអាង ឬខ្លឹមសារនៃកិច្ចសម្ភាសន៍របស់ពួកគេ។ ដោយសារមេធាវីការពារក្ដីត្រូវបានហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងនៅក្នុងក្របខណ្ឌ អ.វ.ត.ក ហេតុនេះ មេធាវីការពារក្ដីពឹងផ្អែកលើសិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្គាប់ឱ្យផ្ដល់ភ័ស្តុតាងចាំបាច់សម្រាប់រៀបចំការការពារក្ដីលោក នួន ជា។

39. អង្គជំនុំជម្រះសាលាដំបូងក៏ត្រូវបានរារាំងមិនឱ្យធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវទៅលើភាពអាចជឿជាក់បាន និងតម្លៃជាភ័ស្តុតាងនៃភ័ស្តុតាងរបស់លោក Hinton ដោយសារពុំមានការយោងច្បាស់លាស់ទៅប្រភពព័ត៌មាននានាដែលជាមូលដ្ឋាននៃយោបល់របស់លោក Hinton ហើយប្រភពព័ត៌មានដែលត្រូវបានយោងច្បាស់លាស់ មិនអាចពិនិត្យមើលបានទេ។ នៅពេលសម្រេចទៅលើ

---

[64] មាត្រា ៣៥(ខ) និង(ង) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

[65] ឯកសារ **E3/9703** 'Volodymyr Dibrova, 'Mapping the Great Famine: a new project at Harvard', Ukrainian Weekly, ថ្ងៃទី ៣០ ខែ មិថុនា ដល់ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១៣" លេខ ERN 01211135 (ភាសាអង់គ្លេស) 2nd column។ ពុំមានការបកប្រែជាភាសាបារាំង ឬភាសាខ្មែរទេ។

សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំទទួលយកផ្នែកនានានៃរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលមានចំណងជើងថា *រយៈពេល ៣០ ឆ្នាំរបស់ ហ៊ុន សែន៖ អំពើហិង្សា ការបង្ក្រាប និងអំពើពុករលួយក្នុងប្រទេសកម្ពុជា* មកធ្វើជាភ័ស្តុតាងនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា របាយការណ៍នោះ "ហាក់ដូចជារបាយការណ៍សង្ខេបចេញពីប្រភពជាច្រើនខុសៗគ្នាដែលបានយោងនៅក្នុងនោះ" ហើយថា របាយការណ៍នេះ "តម្រូវឲ្យមានការពិនិត្យឲ្យបានហ្មត់ចត់លើសម្ភារៈឯកសារដែលបានយោង"[66]។ ជាងនេះទៀត របាយការណ៍បានលើកឡើងជាក់លាក់ថា ឯកសារយោងខ្លះមាន "លក្ខណៈស្រពិចស្រពិល" ហើយ ក្នុងករណីខ្លះ ពុំមានបញ្ជាក់ពីបុគ្គលដែលត្រូវបានសម្ភាសនោះឡើយ[67]។ ចំណុចកំណត់ទាំងនេះក៏អនុវត្តដូចគ្នាចំពោះសៀវភៅ និងភ័ស្តុតាងរបស់លោក Hinton ដែរ ដូចបានលើកឡើងខាងលើ[68]។ នៅពេលសម្រេចទៅលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា របាយការណ៍នេះមិនសមស្របក្នុងការបញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យ មិនមានប្រយោជន៍ចំពោះការស្វែងរកការពិត ហើយហេតុនេះបានជាបដិសេធនោះត្រូវបានបដិសេធមិនទទួលយកធ្វើជាភ័ស្តុតាង[69]។ មេធាវីការពារក្តីលើកឡើងថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងអនុវត្តយ៉ាងច្បាស់លាស់ចំពោះសៀវភៅ និងភ័ស្តុតាងរបស់លោក Hinton ដែរ[70]។ ក្នុងស្ថានភាពបច្ចុប្បន្ន

[66] ឯកសារ **E347/1** "សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) សុំឲ្យទទួលយកឯកសារថ្មីៗដាក់ក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៤ ("ឯកសារ E347/1")។

[67] ឯកសារ **E347/1** កថាខណ្ឌ ៤។

[68] *សូមមើល* ឧទាហរណ៍នានាដែលបានដកស្រង់នៅក្នុងកថាខណ្ឌ ៨ និង ១១ ខាងលើ។

[69] ឯកសារ **E347/1** កថាខណ្ឌ ៤។

[70] ទោះបីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃភាពទទួលយកបាននៃរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលមេធាវីការពារក្តីបានដាក់ គឺជាបទដ្ឋានខ្ពស់ពេកសម្រាប់ដំណាក់កាលនេះក៏ដោយ តែក្នុងករណីនេះ [*សូមមើល* ឯកសារ **E347/2** "សំណើរបស់ នួន ជា សុំឲ្យពិចារណាឡើងវិញក្នុងការទទួលយកអត្ថបទសង្ខេបមួយ និងទទួលយកអត្ថបទសង្ខេបចំនួនពីរបន្ថែមទៀតពីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "រយៈពេល ៣០ ឆ្នាំ នៃការកាន់តំណែងរបស់ ហ៊ុន សែន" ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥] សៀវភៅរបស់លោក Hinton ត្រូវបានទទួលយកជាភ័ស្តុតាងរួចហើយ។ ជាលទ្ធផល បញ្ហាស្តីពីការកំណត់អត្តសញ្ញាណ និងការធ្វើវិភាគចំពោះប្រភពព័ត៌មានរបស់គាត់ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការវាយតម្លៃចំពោះភ័ស្តុតាងរបស់គាត់ និងទម្ងន់ដែលអង្គជំនុំជម្រះសាលាដំបូងផ្តល់ដល់ភ័ស្តុតាងនេះ នៅពេលចេញសាលក្រម។ ជាងនេះទៀត មេធាវីការពារក្តីកត់សម្គាល់ថា ភ័ស្តុតាងរបស់លោក Hinton ត្រូវបានផ្តល់ទៅតាមបទដ្ឋានខ្ពស់ជាងនេះ នៅពេលគាត់មកបង្ហាញខ្លួនក្នុងនាមជាសាក្សីជំនាញ និងជាពិសេសជាអ្នកជំនាញ (ដែលត្រូវបានអះអាង) ស្តីពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាម។

នេះ ការអះអាងរបស់លោក Hinton មិនអាចធ្វើការផ្ទៀងផ្ទាត់បានទេ។ ការប្រមូលផ្ដុំ និងការវិភាគទៅលើប្រភពព័ត៌មានរបស់គាត់មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការវាយតម្លៃទៅលើភ័ស្ដុតាងរបស់គាត់ ដែលជាប្រយោជន៍នៃយុត្តិធម៌នោះ។

## ឃ. សម្ភារៈនានាដែលបានស្នើឡើងមានអត្ថិភាព ហើយស្ថិតក្រោមការគ្រប់គ្រងរបស់លោក Hinton

40. ដូចបានលើកឡើងនៅត្រង់កថាខណ្ឌ ៩ ១២ និង ១៣ ខាងលើ លោក Hinton បានផ្តល់សក្ខីកម្មអំពីអត្ថិភាពនៃសម្ភារៈនានាដែលបានស្នើឡើង។ លើសពីនេះទៀត គាត់បានលើកឡើងទៀតថា សម្ភារៈស្រាវជ្រាវដែលគាត់បានប្រើប្រាស់សម្រាប់និពន្ធសៀវភៅរបស់គាត់ ត្រូវបាន "តម្កល់ទុក" នៅផ្ទះរបស់គាត់ នៅសហរដ្ឋអាមេរិក[71]។

## V. សំណូមពរ

41. ផ្អែកលើសំអាងហេតុនានាដែលបានលើកឡើងខាងលើ មេធាវីការពារក្ដីសូមស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

(ក) បង្គាប់លោក Hinton ផ្ដល់មកឲ្យមេធាវីការពារក្ដីនូវ៖

(១) ការអង្កេតដែលលោក Hinton បានធ្វើឡើងនៅភូមិពោធិ៍ នៅចន្លោះពីឆ្នាំ ១៩៩៤ ដល់ ១៩៩៥ រួមទាំង ចម្លើយនានានៅក្នុងការស្ទាបស្ទង់មតិទាំងនោះ ដែលត្រូវបានអះអាងថា បានផ្ដល់ដោយអ្នកចូលរួមពី ៩៥ ដល់ ១០០ នាក់នោះ។

(២) ខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍របស់លោក Hinton ជាមួយ "អ្នកផ្ដល់ព័ត៌មានសំខាន់ៗ" របស់គាត់ និងខ្សែអាត់សំឡេងផ្សេងទៀតដែលលោក Hinton បានថតនៅពេលសម្ភាសបុគ្គលនានាដើម្បីសរសេរសៀវភៅរបស់គាត់ ព្រមទាំងប្រតិចារឹកនៃកិច្ចសម្ភាសន៍ទាំងនេះជាភាសាខ្មែរ និងការបកប្រែជាភាសាអង់គ្លេសបើមាន។

(៣) កំណត់ត្រារបស់លោក Hinton ដែលបានធ្វើឡើង ដោយផ្អែកទៅលើ "ការសង្កេតទៅលើអ្នកចូលរួម" របស់គាត់ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរផ្សេងទៀត

[71] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/402.1**) ទំព័រ ១៦ បន្ទាត់ ៨ ដល់ ៩។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (HINTON Alexander L. ឯកសារ **E1/403.1**) ទំព័រ ៥ បន្ទាត់ ១៩ ដល់ ២០។

ពីកិច្ចសម្ភាសន៍ "ក្រៅផ្លូវការ" របស់គាត់។ និង

(៥) "ក្រដាសលេខកូដ" ដែលលោក Hinton បានលើកឡើង នៅក្នុងសក្ខីកម្មរបស់គាត់។

(ខ) ផ្ដល់ឱកាសដល់ភាគីក្នុងការធ្វើសេចក្ដីសន្និដ្ឋានថាតើ គួរទទួលយកប្រភពព័ត៌មានទាំងនោះធ្វើជាភស្តុតាង ឬយ៉ាងណា។ និង

(គ) ផ្ដល់ឱកាសដល់ភាគីក្នុងការធ្វើសេចក្ដីសន្និដ្ឋានថាតើ ត្រូវមានវិធានការអ្វីបន្ថែមទៀតទាក់ទិននឹងព័ត៌មានដែលទទួលបានពីការស៊ើបអង្កេតបន្ថែមទៀតនោះ។

**សហមេធាវីការពារក្ដី នួន ជា**

សុន អរុណ Victor KOPPE